ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៧/២០-ហឺរ៉ាយហ្សិន អៅជរ (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ កុយ នាម

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅជរ** (ខេមបូឌា)
អាសយដ្ឋាន ៖ ភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០៧៧ ៧៧៧ ៥៦៤ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោកស្រី ជី គុន្ធា នាយករដ្ឋបាល
២- លោក ជា ចុង អ្នកគ្រប់គ្រងទេ
៣- លោកស្រី ផង់ តិចលីម ជំនួយការរដ្ឋបាល
៤- កញ្ញា វ៉េត ធយី ជំនួយការរដ្ឋបាល
៥- កញ្ញា កែវ សុផារី ជំនួយការរដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅជរ** (ខេមបូឌា)
អាសយដ្ឋាន ៖ ភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០៧០ ៧១ ៦១ ៩៣ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖ ទូរសារ ៖ គ្មាន

១- លោក ម៉ៃ ម៉ា មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត
២- លោក ប៊ុត ប៊ុនឈាន មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត

៣- លោកស្រី សៀក ហុង ប្រធានសហជីព (មូលដ្ឋាន)

៤-លោកស្រី រឿន កុលាប អនុប្រធានសហជីព (មូលដ្ឋាន)

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបើកទ្វាររោងចក្រអគារនីមួយៗ រៀងរាល់ម៉ោងចេញ ចូល បំពេញការងារ។ ដោយឡែក ភាគីក្រុមហ៊ុនមិនឯកភាពបើកច្រកចេញ ចូល បន្ថែមទៀតនោះទេ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុន ត្រូវបញ្ឈប់ជាបន្ទាន់រាល់សកម្មភាព ឃុបឃិតកេងប្រវ័ញ្ច ដែលបំពាននិងគោលការណ៍ច្បាប់ ក្នុងការកាត់ប្រាក់ឈ្នួលយើងខ្ញុំបង់ភាគទានសហជីពឱ្យសហជីពសិទ្ធប្រយោជន៍កម្មករ ហើយក្រុមហ៊ុនត្រូវសងប្រាក់ដែលបានឃុបឃិតកេងប្រវ័ញ្ចកន្លងមក ជូនយើងខ្ញុំវិញ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ពុំមានការឃុបឃិតកេងប្រវ័ញ្ចនោះទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅដរ (ខេមបូឌា) លេខ ១០០៥ កប/កផ ចុះថ្ងៃអង្គារ ៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំងបានទទួលលិខិតស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររបស់ភាគីកម្មករនិយោជិត ស្តីពីការទាមទាររបស់កម្មករនិយោជិត សុំឱ្យក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅដរ (ខេមបូឌា) ដោះស្រាយលក្ខខណ្ឌការងារចំនួន ៩ចំណុច។ ក្រុមហ៊ុន ហឺរ៉ាយ

ហ្សិន អៅជរ (ខេមបូឌា) មានសហជីពសិទ្ធិប្រយោជន៍កម្មករ ជាហជីពដែលមានភាពជាតំណាងបំផុតព្រមទាំងបានចុះអនុសញ្ញារួមរួចរាល់ហើយ ទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ហើយចំពោះចំណុចទាមទារទាំង ៩ចំណុច គឺមានចែងនៅក្នុងអនុសញ្ញារួមចំនួន ៦ចំណុច នៅសល់ចំនួន ៣ចំណុចទៀត គឺមិនមាននៅក្នុងអនុសញ្ញារួម ដូច្នេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង បានធ្វើការផ្សះផ្សានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ចំណុច។ ចំណុចមិនសះជាចំនួន ២ចំណុចទៀត ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅជរ (ខេមបូឌា) លេខ ១០០៥ កប/កធ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២១។ ស្របពេលនេះដែរ ដោយសារតែការរីករាលដាលឆ្លងចូលសហគមន៍នៃជំងឺកូវីដ-១៩ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ និងមានកម្មករនិយោជិតមួយចំនួន នៃក្រុម ហឺរ៉ាយហ្សិន អៅជរ (ខេមបូឌា) មានពាក់ព័ន្ធនឹងការឆ្លងនៃជំងឺកូវីដ-១៩ ភាគីទាំងពីរបានព្រមព្រៀងគ្នាស្នើសុំព្យួរនីតិវិធីអាជ្ញាកណ្តាល តាមរយៈលិខិតចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២១។ បន្ទាប់ពីបានទទួល និងពិនិត្យលើលិខិតស្នើសុំព្យួរនីតិវិធីអាជ្ញាកណ្តាល ក្រុមអាជ្ញា-កណ្តាលបានសម្រេចឯកភាពតាមសំណើរបស់ភាគីទាំងពីរ។

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ របស់ភាគីកម្មករនិយោជិត ស្តីពីការស្នើសុំបន្តនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើងវិញ។ ភាគីនិយោជកក៏បានឯកភាពទៅនឹងការស្នើសុំរបស់ភាគីកម្មករនិយោជិតដែរ។ ក្រុមអាជ្ញាកណ្តាលបានទទួល និងពិនិត្យលើសំណើរបស់ភាគីទាំងពីរ និងបានកំណត់ថ្ងៃសវនាការ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០នាទី ព្រឹក។ ប៉ុន្តែ ដោយសារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលមានបុគ្គលិកមានវិជ្ជមានកូវីដ-១៩ ហើយដើម្បីគោរពតាមវិធានការសុខាភិបាល និងបង្ការការឆ្លងរាលដាលបន្តនៅក្រុមប្រឹក្សាអាជ្ញា-កណ្តាល ហេតុនេះ ការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបិទ ដែលធ្វើឱ្យមានការពន្យារពេលសវនាការ ហើយភាគីទាំងពីរក៏បានឯកភាពលើការពន្យារនីតិវិធីសវនាការអាជ្ញាកណ្តាលនេះផងដែរ។ ក្រុមអាជ្ញាកណ្តាលបានកំណត់ថ្ងៃសវនាការ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០នាទី រសៀល នៅទីស្នាក់ការនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាទាំង ២ចំណុច តាមការកំណត់របស់ក្រុមអាជ្ញា-កណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសដើម្បីរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលបានធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្ស៊ូម (zoom) ដោយបានចែកបន្ទប់រវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល ដាច់ដោយឡែកពីគ្នា។ ភាគីទាំងពីរមិនជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែករកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្ដល់ឯកសារ និងភស្តុតាង និងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ និងភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារពេលបរិច្ឆេទនៃការចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតចុះថ្ងៃសុក្រ ៦កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់តំណាងភាគីនិយោជក នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) និងអ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំព្យួរនីតិវិធីក្រុមប្រឹក្សា-អាជ្ញាកណ្ដាលសំណុំរឿងលេខ ០០៧/២១-ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

២- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ របស់លោក ដាវិន វីដចាចា (Darwin Widjaja) ជានាយកក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញា-កណ្ដាល ស្ដីពីសំណើសុំផ្ទេរសិទ្ធិជូនលោកស្រី ជី គុន្ធា ជានាយករដ្ឋបាល លោកស្រី ផង់ គិចលីម លោក ជា ថុង កញ្ញា វ៉េត ធយី និងកញ្ញា កែវ សុផារី ជាបុគ្គលិកផ្នែករដ្ឋបាល មានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ក្នុងនាមឱ្យម្ចាស់ ឬនាយក ក្រុមហ៊ុន។

៣- លិខិតចុះថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០២១ របស់ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីជូនសារណាសង្ខេបវិវាទការងាររួមក្នុងសំណុំរឿងលេខ ០០៧/២១-ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា)។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) លេខ MOC ៤២៤១៩៦១ ពណ.ចបព ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២។

៥- សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) បានចុះ[illegible] DE២០២១១១៤៣ អធក ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០២១។

៦- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) លេខ ៥១៥៣/២០១៦ អគ ប/អពជ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥។

៧- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) លេខ PTL-២០២១០១៧៩៧៣ អពជ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១។

៨- ប្រកាសបង្កើតរោងចក្រ ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) លេខ ០២៥ ឧសក ឧ.ប្រក០១ របស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧។

៩- លក្ខន្តិកៈក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) បានតម្កល់ទុកលេខ ០០០១៨៣៩០ គ.រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

១០- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) ចុះបញ្ជិកាលេខ ២៩៨ រ.ប/ក.ធ ចុះថ្ងៃ ទី២២ ខែមករា ឆ្នាំ២០១៥ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង។

១១- លិខិតចុះថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២០ របស់នាយកក្រុមហ៊ុនផលិតកាបូបគ្រប់ប្រភេទ និងសម្លៀកបំពាក់ ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ស្តីពីសំណើសុំចុះបញ្ជីកាលើអនុសញ្ញារួម។

១២- អនុសញ្ញារួមនៃការងារ រវាងក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) និងសហជីពសិទ្ធិប្រយោជន៍ កម្មករ នៃរោងចក្រ ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) អាណត្តិទី៣ បានចុះបញ្ជីលេខ ០១០ កប/ អក/វក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- វិញ្ញាបនបត្របញ្ជាក់ពីភាពតំណាងបំផុតរបស់សហជីពសិទ្ធិប្រយោជន៍កម្មករ នៃក្រុមហ៊ុន ហ៏រ៉ាយ ហ្សិន អៅដ៌រ (ខេមបូឌា) លេខ ៥០១/១៩ ក.ប/វ.ប.វ.ក ចុះថ្ងៃព្រហស្បតិ៍ ២កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

១៤- លិខិតលេខ ១២៤៤ កប/អក/វក ចុះថ្ងៃពុធ ១០កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវ នឹងថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់នាយកដ្ឋានវិវាទការងារ ជម្រាបមក លោកនាយកក្រុមហ៊ុន Horizon Outdoor (Cambodia) Co., Ltd ស្តីពីជូនដំណឹងអំពីការដាក់ពាក្យស្នើសុំភាពជា តំណាងបំផុតរបស់សហជីពសិទ្ធិប្រយោជន៍កម្មករនៃក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា)។

១៥- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពសិទ្ធិប្រយោជន៍កម្មករ នៃក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) លេខ ១១៩០ កប/កធ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។

១៦- លិខិតលេខ ១២៤៨ កប/កធ ចុះថ្ងៃពុធ ៣កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃ ទី៣០ ខែតុលា ឆ្នាំ២០១៩ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង ជម្រាបមក លោកនាយកក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) ស្តីពីការស្នើសុំទទួលស្គាល់ ថ្នាក់ដឹកនាំសហជីព និងលក្ខន្តិកៈថ្មី។

១៧- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ (ខេមបូឌា) លេខ ១១៨៦ កប/កធ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។

១៨- លិខិតលេខ ១១៨៥ កប/កធ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ហ៏រ៉ាយហ្សិន អៅដ៌រ

THE ARBITRATION COUNCIL

(ខេមបូឌា) ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ។

១៩- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពអំណាចយុវជន នៃក្រុមហ៊ុន ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) លេខ ១៤៣៨ កប/កធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

២០- លិខិតលេខ ២៨៧/២១ កប/កធ ចុះថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែមេសា ឆ្នាំ២០២១ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង ជម្រាបមក លោកប្រធានសហជីពអំណាចយុវជន នៃក្រុមហ៊ុន ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

២១- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពកម្មករកម្ពុជារោងចក្រ ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) លេខ ១៧៦ កប/កធ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១។

២២- លិខិតលេខ ១៧៧ កប/កធ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករកម្ពុជា រោងចក្រ ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ។

២៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពកម្ពុជានៃក្រុមហ៊ុន ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) លេខ ១៣៨ កប/កធ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

២៤- លិខិតលេខ ១៣៧ កប/កធ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពសហជីពកម្ពុជា នៃក្រុមហ៊ុន ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

២៥- ច្បាប់ស្តីពីសហជីពទំព័រទី១ ទី៥ និងទី៦។

២៦- លិខិតលេខ ១២៥ កប/អក/វក ចុះថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជម្រាបជូន នាយកក្រុមហ៊ុន ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) ស្តីពីការស្នើសុំបំភ្លឺពាក់ព័ន្ធនឹងការកាត់វិភាគទានរបស់សហជីព ករណីកម្មករនិយោជិតជាសមាជិកសហជីពសិទ្ធិប្រយោជន៍កម្មករនៃក្រុមហ៊ុន ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) បានលាលែងពីសមាជិកភាពនៃសហជីពនេះទៅចូលរួមជាមួយសហជីពដទៃ។

២៧- លិខិតចុះថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ របស់នាយកក្រុមហ៊ុនផលិតកាបូបគ្រប់ប្រភេទ និងសម្លៀកបំពាក់ ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា) គោរពជូន នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីស្នើសុំបំភ្លឺអំពីការកាត់វិភាគទានរបស់សហជីពនៅក្នុងរោងចក្រ ហ៉ីរ៉ាយហ្សិន អៅជរ (ខេមបូឌា)។

THE ARBITRATION COUNCIL

២៨- ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា ២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីពដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ ២០២០។

២៩- ប្លង់រត់ជម្លៀសពេលមានអាសន្នក្នុងបរិវេណរោងចក្រទាំងមូល។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃសុក្រ ៦កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២១ របស់តំណាងភាគីនិយោជក នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) និងអ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំព្យួរនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ០០៧/២១-ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- លិខិតចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំដំណើរការនិតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ០០៧/២១-ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១។

៣- លិខិតស្នើសុំកាត់ភាគទានរបស់សហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ជាសាខាសហព័ន្ធសហជីពកម្មករនិយោជិត គោរពចូលមក នាយកក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ស្តីពីសំណើរកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីព ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។

៤- ពាក្យលាលែងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) គោរពជូន ប្រធានសហជីពសិទ្ធិប្រយោជន៍កម្មករ ស្តីពីជូនដំណឹងស្តីពីការលាលែង។

៥- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) លេខ ១១៤៦ កប/កធ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។

៦- លិខិតលេខ ៥៨៤ ក.ប/ក.ធ ចុះថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៩ របស់ប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង ជម្រាបមក លោកស្រីប្រធានសហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) លេខ ១០០៥ កប/កធ ចុះថ្ងៃអង្គារ ៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២១។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) លេខ ០០៣/២១ ក.ប/ក.ធ.ល.ប.រ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ ២០២១ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៧០ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៧១ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១០២ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១០៣ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) មានសកម្មភាពចម្បងផ្នែកផលិតកាបូប និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០១៨៣៩០ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១២។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៨២៤៣នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) លេខ ១០០៥ កប/កធ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១)*
- ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) មានសហជីពសិទ្ធិប្រយោជន៍កម្មករនៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) ជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុន និងបានចុះអនុសញ្ញារួម នៃការងារសម្រាប់អាណត្តិទី៣ ដែលមានសុពលភាព ចាប់ពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ដល់ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២៣ និងបានចុះបញ្ជីលេខ ០១០ កប/អក/វក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។
- សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅជរ (ខេមបូឌា) ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខចុះបញ្ជី ១០៤១៧០០២២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព លេខ ៥៨៤ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ដែលមានថ្នាក់ដឹកនាំចំនួន ៣នាក់ គឺ ១. លោកស្រី សៀក ហុង ជាប្រធាន, ២. លោកស្រី ឆឹង សុខលី ជាអនុប្រធាន, និង៣. លោកស្រី យ៉ង់ ស្រីលីន ជាលេខាធិការិនី។

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០០៣/២១ កប/ក.ធ.ល.ប.វ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ ២០២១ ដែលមានកម្មករនិយោជិតចំនួន ២នាក់ រួមមាន ៖ ១.ឈ្មោះ សៀក ហុង និង២. ឈ្មោះ រឿន កុលាប។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកទ្វារច្រកអគារនីមួយៗ រៀងរាល់ម៉ោងចេញចូល បំពេញការងារ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកច្រកទ្វារតាមអគារនីមួយៗ បន្ថែមចំនួន ១ ទៀត ដើម្បីឱ្យកម្មករនិយោជិតចេញចូលអគារ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - នៅក្នុងក្រុមហ៊ុនមានអគារសរុបចំនួន ៩ ដោយអគារនីមួយៗ មានច្រកទ្វារមិនដូចគ្នានោះទេ អគារខ្លះមានច្រកទ្វារចំនួន ៤, ៦, ៧ និង៨ និងច្រកទ្វារនីមួយៗ មានប្រវែង ៥ម៉ែត្រ។
  - នៅក្នុងអគារនីមួយៗ មានកម្មករនិយោជិតចំនួនប្រហែល ១០០០នាក់។
  - និយោជកបើកច្រកទ្វារតែមួយប៉ុណ្ណោះ នៅពេលកម្មករនិយោជិតចេញចូលធ្វើការ និងពេលចេញទៅពិសាអាហារថ្ងៃត្រង់។
  - កន្លងមក មិនមានកម្មករនិយោជិតណាម្នាក់មានបញ្ហា ឬមានគ្រោះថ្នាក់ដោយសារការចេញចូលតាមច្រកទ្វារតែមួយនោះទេ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ការបើកច្រកទ្វារបន្ថែម អាចឱ្យកម្មករនិយោជិតរក្សាគម្លាតពីគ្នា និងចំណេញវេលាពេលចេញចូលអគារ។
  - នៅពេលកម្មករនិយោជិតចេញពិសាអាហារថ្ងៃត្រង់ម្តងៗ ត្រូវចំណាយពេលប្រហែល ១០ ទៅ ១២នាទី ដើម្បីចេញពីក្នុងអគារ។
  - ផ្អែកតាមគោលការណ៍របស់ក្រសួងសុខាភិបាល គឺតម្រូវឱ្យកម្មករនិយោជិតរក្សាគម្លាតពីគ្នាឱ្យបាន ១,៥ម៉ែត្រ ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ បច្ចុប្បន្ននេះ កម្មករនិយោជិតមានការប្រជ្រៀតគ្នាចេញ និងមានស្ថានភាពចង្អៀត ហើយពួកគាត់បារម្ភពីការឆ្លងជំងឺកូវីដ-១៩។
  - ប្រសិនបើនិយោជកគង់តែរៀបចំឱ្យមានសន្តិសុខពិនិត្យតាមច្រកទ្វារចេញចូលដដែល និយោជកអាចបន្ថែមសន្តិសុខ និងបើកទ្វារមួយទៀត ដើម្បីជួយសម្រួលកម្មករនិយោជិតអាចចេញទៅពិសាអាហារថ្ងៃត្រង់បានស្រួល មានពេលសម្រាកគ្រប់គ្រាន់ និងសមស្របតាមស្ថានការណ៍កូវីដ-១៩។
  - និយោជកដាក់វិធានការសុវត្ថិភាព បណ្តាលឱ្យយឺតកាន់តែខ្លាំង ដោយសារការកកស្ទះក្នុងអគារ នៅពេលល្ងាចត្រូវចំណាយពេលចន្លោះពី ១២ ទៅ១៥នាទី ទើបដល់មាត់ច្រកទ្វារធំចេញពីរោងចក្រ ហើយកម្មករនិយោជិតប្រញាប់ចេញទៅចាំឡានមុន ព្រោះឡានមិនចាំពួកគាត់នោះទេ។

THE ARBITRATION COUNCIL

- ០ មិនមានបទប្បញ្ញត្តិណាមួយចែងអំពីចំណុចនេះនោះទេ ប៉ុន្តែការទាមទារនេះយោងតាមវិធានការសុវត្ថិភាព ដើម្បីរក្សាសុវត្ថិភាពរបស់កម្មករនិយោជិត។ ម្យ៉ាងទៀត នៅក្នុងច្បាប់ស្តីពីការងារក៏បានលើកឡើងពីសុខសុវត្ថិភាពនៃកន្លែងការងារ ហើយនិយោជកគួរតែអនុវត្តតាម។

- ភាគីនិយោជកបញ្ជាក់មូលហេតុដែលផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយហេតុថា ៖
  - ០ ចំពោះការបើកច្រកទ្វារ ៖
    - យោងតាមប្រការ ៩ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន នៅពេលកម្មករនិយោជិតចេញ ឬចូលធ្វើការត្រូវគោរពតាមការណែនាំរបស់ក្រុមហ៊ុន។
    - និយោជកអនុវត្តបើកច្រកទ្វារចេញចូលអគារនីមួយៗ ចំនួន ១ តាំងពីបើកក្រុមហ៊ុនមកម្ល៉េះ គឺដើម្បីរក្សាសន្តិសុខ សុវត្ថិភាព និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទាំងមូល។ ម្យ៉ាងទៀត និយោជកត្រូវរៀបចំឱ្យមានសន្តិសុខធ្វើការពិនិត្យទាំងម៉ោងចេញ និងម៉ោងចូល ដើម្បីធានាថា កម្មករនិយោជិតមិនយកនំចំណីចូលក្នុងអគារដែលអាចធ្វើឱ្យប្រលាក់របស់មានតម្លៃ ឬមានការលួចយកអីវ៉ាន់របស់ក្រុមហ៊ុនជាដើម។
    - និយោជករៀបចំសន្តិសុខចំនួន ៥ ទៅ ៦នាក់ ក្នុងមួយអគារ ដើម្បីធ្វើការឆែកឆេរកម្មករនិយោជិតទាំងអស់ គឺបង្ការការបាត់អីវ៉ាន់ ព្រោះប្រសិនបើភ្លៀវចាប់បាន នឹងបញ្ឈប់ការបញ្ជាទិញ។
    - ប្រសិនបើនិយោជកបើកច្រកទ្វាអគារមួយទៀត នោះកម្លាំងសន្តិសុខឆែកឆេរនឹងមានការបែងចែក មិនអាចមើលគ្រប់ជ្រុងជ្រោយ ព្រោះកន្លងមកមានកម្មករនិយោជិតយកអីវ៉ាន់ចេញ។
    - ទោះបីជានិយោជកមិនបានបើកច្រកទ្វារផ្សេងៗទៀតមែន តែនិយោជកមិនបានចាក់សោរទ្វារទាំងនោះទេ ករណីមានអាសន្នណាមួយ កម្មករនិយោជិតអាចបើកទ្វារចេញបាន។
  - ០ ចំពោះគោលការណ៍បង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ៖
    - និយោជកមានការប្រជុំប្រាប់ប្រធានក្រុម ប្រធានផ្នែក និងបុគ្គលិកបកប្រែ និងបានជម្រាបជូនកម្មករនិយោជិត ២ ទៅ ៣ដង ក្នុងមួយសប្តាហ៍ តាមរយៈឧបករណ៍បំពងសំឡេងអំពីការរក្សាគម្លាតសុវត្ថិភាព និងអនុវត្ត ៣កុំ ៣ការពារ។
    - សម្រាប់ម៉ោងចេញទៅពិសាអាហារបាយថ្ងៃត្រង់ មិនមានបញ្ហាក្នុងការដើរចេញពីអគាររោងចក្រនោះទេ ប៉ុន្តែចំពោះម៉ោងចេញទៅផ្ទះ មានកម្មករនិយោជិតខ្លះនាំគ្នារត់ចេញពីក្នុងអគារប្រញាប់បានទៅផ្ទះ។
    - និយោជកបានរៀបចំបរិវេណសម្រាប់កម្មករនិយជិតដើរមានចន្លោះប្រវែង ៨ ទៅ ១០ ម៉ែត្រ ដែលអាចឱ្យកម្មករនិយោជិតរក្សាគម្លាតពីគ្នាបានពេលដើរទៅស្ពានចេញទៅផ្ទះ។
    - និយោជកបានគូសគំនូសគម្លាតសុវត្ថិភាពសម្រាប់ដើរ រៀបចំរនាំងចំនួន ៤ ទៅ ... ប្រឡោះ នៃអគារនីមួយៗ ដើម្បីឱ្យកម្មករនិយោជិតបែងចែកគ្នាដើរ នឹងចុះរនាំង...

THE ARBITRATION COUNCIL

កម្មករនិយោជិតកុំឱ្យមានការប្រជែងគ្នា តែកម្មករនិយោជិតនៅតែនាំគ្នាសម្រុកចេញដោយមិនស្តាប់ការណែនាំ។

- និយោជកបានរៀបចំការរក្សាគម្លាតសុវត្ថិភាព ប៉ុន្តែទាំងមុន និងក្រោយស្ថានភាពជំងឺកូវីដ-១៩ កម្មករនិយោជិតនៅតែអនុវត្តការដើរចេញដដែល។
- កម្មករនិយោជិតចំណាយពេលដើរចេញពីក្នុងអគាររោងចក្រត្រឹមតែ ៣ ទៅ ៤នាទី ប៉ុណ្ណោះ ហើយទៅដល់កន្លែងស្កេនចន្លោះពី ៦ ទៅ ៧នាទី ហើយអាចដល់ ១០នាទី សម្រាប់ថ្ងៃសៅរ៍។
- និយោជកបានរៀបចំឡានចំនួន ៧៦គ្រឿង នៅមុខរោងចក្រ ដើម្បីដឹកជញ្ជូនកម្មករនិយោជិត នៅពេលកម្មករនិយោជិតទាំងអស់បានឡើងឡានពេញអស់ ទើបនិយោជកអនុញ្ញាតឱ្យឡានចេញបាន។
- បច្ចុប្បន្ននេះ និយោជកបានចូលជាសមាជិកអង្គការ អេ អាយ ធី ទាក់ទងនិងសុវត្ថិភាពចរាចរណ៍ ដែលមានការចូលរួមពីប៉ូលីសចរាចរណ៍ អាជ្ញាធរមានសមត្ថកិច្ច និងគណៈកម្មការសុខភាពសុវត្ថិភាពសម្រាប់កម្មករនិយោជិតប្រចាំក្រុមហ៊ុន ដើម្បីពិនិត្យមើលលើសុវត្ថិភាពគ្រប់គ្រាន់ក្នុងការដឹកកម្មករនិយោជិត។
- ជាងនេះទៀត ទោះបីជានិយោជកបើកច្រកទ្វារតាមអគារបន្ថែមមួយទៀត ក៏មិនមានភាពខុសគ្នាដែរ ពីព្រោះកម្មករនិយោជិតនៅតែប្រជ្រៀតគ្នាចេញ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក បញ្ឈប់ជាបន្ទាន់រាល់សកម្មភាពឃុបឃិតកេងប្រវ័ញ្ចដែលបំពាននឹងគោលការណ៍ច្បាប់ក្នុងការកាត់ប្រាក់ឈ្នួលកម្មករនិយោជិតបង់ភាគទានឱ្យសហជីពសិទ្ធិប្រយោជន៍កម្មករ ហើយនិយោជកត្រូវសងប្រាក់ដែលបានឃុបឃិតកេងប្រវ័ញ្ចកន្លងមកជូនកម្មករនិយោជិតវិញ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីពតាមការស្នើសុំរបស់សមាជិកសហជីពកម្មករនិយោជិតចំនួន ២០០០រៀល ទៅឱ្យសហជីពកម្មករនិយោជិត ចាប់ពីខែកញ្ញា ឆ្នាំ២០២១។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ចាប់តាំងពីខែឧសភា ឆ្នាំ២០២០ មកសហជីពបានលិខិតបញ្ជាក់ពីកម្មករនិយោជិតដែលចូលជាសមាជិកសហជីពចំនួន ១៥៧នាក់ និងបានដាក់ពាក្យស្នើសុំកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតទាំងនេះ ជូននិយោជក តែនិយោជកបដិសេធមិនព្រមកាត់ភាគទានឱ្យនោះទេ ដោយលើកហេតុផលថា ពួកគាត់ជាសមាជិកសហជីពសិទ្ធិប្រយោជន៍កម្មករ។
  - ចំពោះកម្មករនិយោជិតទាំង ១៥៧នាក់ មានលិខិតផ្តិតមេដៃលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករ និងបានដាក់លិខិតជូនដំណឹងទៅសហជីពសិទ្ធិប្រយោជន៍កម្មករ និងដាក់ជូនទៅនិយោជករួចហើយ តែនិយោជកនៅតែកាត់ភាគទានឱ្យទៅសហជីពសិទ្ធិប្រយោជន៍កម្មករដដែល។
  - ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះកម្មករនិយោជិត និងលិខិតលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករ ប៉ុន្តែនិយោជកមិនព្រមកាត់ប្រាក់ភាគទានជូនសហជីពកម្មករនិយោជិតនោះទេ។
  - និយោជកមានការឃុបឃិត និងកេងប្រវ័ញ្ចដោយហេតុថា ៖

- កាលពីមុនកម្មករនិយោជិតឈ្មោះ រឿន កុលាប គឺជាសមាជិកសហជីពសិទ្ធិប្រយោជន៍កម្មករ ប៉ុន្តែបច្ចុប្បន្ននេះ គាត់ជាថ្នាក់ដឹកនាំសហជីពកម្មករនិយោជិត ហើយគាត់បានធ្វើលិខិតលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មកររួចហើយ តែនិយោជកនៅតែកាត់ប្រាក់ឈ្នួលរបស់គាត់ឱ្យទៅសហជីពសិទ្ធិប្រយោជន៍កម្មករដដែល។
- សហជីពសិទ្ធិប្រយោជន៍កម្មករ និងនិយោជកត្រូវគ្នា ទើបនិយោជកមិនព្រមលុបឈ្មោះកម្មករនិយោជិតចេញពីសហជីពសិទ្ធិប្រយោជន៍កម្មករនោះទេ។

  - និយោជកជ្រៀតជ្រែកការងារសហជីព ដោយនៅពេលដែលកម្មករនិយោជិតស្នើសុំចូលជាសមាជិកសហជីព និយោជកបានណែនាំឱ្យពួកគាត់ចូលសហជីពនេះ ឬសហជីពនោះ។
  - យោងតាមកថាខណ្ឌ ២ នៃមាត្រា ១២៩ នៃច្បាប់ស្ដីពីការងារ ដែលកម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានដែលខ្លួនជាសមាជិក និងមាត្រា ២៨០ នៃច្បាប់ស្ដីពីការងារ ដែលហាមឃាត់រាល់អំពើជ្រៀតជ្រែកទាំងឡាយ។
  - យោងតាមមាត្រា ៧ នៃច្បាប់ស្ដីពីសហជីពបាននិយាយច្បាស់ពីសិទ្ធិសេរីភាពរបស់កម្មករនិយោជិតក្នុងការចេញចូលសហជីព តែនិយោជកមិនបានអនុវត្ត។

- ភាគីនិយោជកបញ្ជាក់មូលហេតុដែលផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយហេតុថា ៖
  - និយោជកសូមច្រានចោលការចោទប្រកាន់របស់ភាគីកម្មករនិយោជិតដែលចោទថា និយោជកមានសកម្មភាពឃុបឃិតកេងប្រវ័ញ្ចដែលបំពាននឹងគោលការណ៍ច្បាប់ក្នុងការកាត់ប្រាក់ឈ្នួលកម្មករនិយោជិតបង់ភាគទានឱ្យសហជីពសិទ្ធិប្រយោជន៍កម្មករ។
  - និយោជកមិនដែលមានការឃុបឃិតកេងប្រវ័ញ្ច ឬកេងប្រវ័ញ្ច ក្នុងការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតណាម្នាក់ទៅឱ្យសហជីពមួយណានោះទេ ពីព្រោះមាននីតិវិធីនៃកាត់ភាគទានរបស់សហជីព។
  - និយោជកកាត់ប្រាក់ភាគទានសហជីព គឺបានទៅសហជីព មិនមែនបានមកនិយោជកនោះទេ ហើយនិយោជកគ្រាន់តែមានភារកិច្ចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីបង់ប្រាក់ភាគទានសហជីពជាប្រចាំខែតែប៉ុណ្ណោះ។
  - ចំពោះការកាត់ប្រាក់ភាគទានសហជីព គឺមានចែងនៅក្នុងប្រការ ១០ នៃអនុសញ្ញារួមរវាងក្រុមហ៊ុនជាមួយសហជីពមានភាពជាតំណាងបំផុត។
  - នៅពេលមានលិខិតលាលែងពីសហជីពចាស់ត្រឹមត្រូវ គឺនិយោជកកាត់ប្រាក់ភាគទានជូនសហជីព ហើយកន្លងមក និយោជកមិនបានទទួលលិខិតលាលែងសហជីព ពីកម្មករនិយោជិតនោះទេ។
  - កន្លងមក និយោជកបានទទួលបញ្ជីឈ្មោះចូលជាសមាជិកសហជីព ដោយនិយោជកបានពន្យល់ទៅសហជីពកម្មករនិយោជិត ឱ្យអនុវត្តទៅតាមប្រការ ១០ នៃអនុសញ្ញារួម ទើបនិយោជកកាត់ភាគទានសហជីពជូន។

- យោងតាមឯកសារភស្តុតាងរបស់ភាគីកម្មករនិយោជិត បានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញ ៖

- លិខិតស្តីពីការស្នើសុំកាត់ភាគទានសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ហ៊ីវាយហ្សិន អៅផរ (ខេមបូឌា) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមាន ឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតចំនួន ១៥៧នាក់។
- លិខិតស្តីពីការលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករ និងការមិនអនុញ្ញាតឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលក្នុងការបង់ភាគទានសិទ្ធិប្រយោជន៍កម្មករ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ដែលមានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតចំនួន ១៣៨នាក់។

## ហេតុផលនៃសេចក្តីសម្រេច ÷

### ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកច្រកទ្វារតាមអគារនីមួយៗ បន្ថែមចំនួន ១ទៀត ដើម្បីឱ្យកម្មករនិយោជិតចេញចូលអគារ

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ការបើកច្រកទ្វារបន្ថែមចំនួនមួយទៀត គឺអាចឱ្យកម្មករនិយោជិតរក្សាគម្លាតពីគ្នា និងចំណេញពេលវេលាចេញចូលអគារ ព្រោះថា សព្វថ្ងៃកម្មករនិយោជិតចំណាយពេលច្រើនដើម្បីរង់ចាំចេញពីអគារដែលធ្វើឱ្យខាតពេលសម្រាកពេលថ្ងៃត្រង់ និងខាតពេលទៅរង់ចាំឡានពេលចេញទៅផ្ទះ និងដើម្បីគោរពតាមគោលការណ៍របស់ក្រសួងសុខាភិបាលដែលតម្រូវឱ្យកម្មករនិយោជិតរក្សាគម្លាតពីគ្នាឱ្យបាន ១,៥ ម៉ែត្រ ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកច្រកទ្វារតាមអគារនីមួយៗបន្ថែមចំនួន ១ទៀត ដែរ ឬទេ?

កថាខណ្ឌទី២ មាត្រា ២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា៖ *"សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ អាចប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជា ក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក"*។

តាមរយៈកថាខណ្ឌទី ២ មាត្រា ២ នៃច្បាប់ស្តីពីការងារខាងលើ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះត្រូវបានធ្វើឡើងដោយស្របច្បាប់ និងសមហេតុផល។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី៥, លេខ ១០៨/០៦-ទ្រីនុងហ្គាល កូម៉ាក់, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣, ៣៩/០៩-ឃ្វីនធ៍ មេជើរ ហេតុផលចំណុចវិវាទទី២, លេខ ១១៩/០៩-អេស អិល ហេតុផលនៃចំណុចវិវាទទី៤ និងទី៥ និងលេខ ០២៩/១៥-ប្រ៊ីជីស អ៊ីម៉ើរ៉ិន ប៊ីប៊ែកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៣ ទី៤ និងទី៥)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើនេះដែរ។

កថាខណ្ឌទី១ មាត្រា៧ នៃអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចែងថា ៖ *"ការរក្សាគម្លាតសុវត្ថិភាពបុគ្គល ត្រូវមានយ៉ាងតិច ១,៥០ ម៉ែត្រ (មួយម៉ែត្រ ហាសិបសង់ទីម៉ែត្រ) ហើយត្រូវអនុវត្តជាកាតព្វកិច្ចនៅកន្លែងធ្វើការ..."*។

THE ARBITRATION COUNCIL

កថាខណ្ឌទី៣ មាត្រា៧ នៃអនុក្រឹត្យលេខ ៣៧ អនក្របក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ខាងលើ ដដែលចែងថា៖ *"រាល់សហគ្រាសគ្រឹះស្ថានឯកជន...ត្រូវរៀបចំនៅក្នុងទីកន្លែងរបស់ខ្លួន ដើម្បីធានាថាបុគ្គលិក ...អាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល នៅពេលរង់ចាំចូល និងពេលកំពុងស្ថិតក្នុងកន្លែងធ្វើការរបស់ខ្លួន។...*"។

ផ្អែកតាមកថាខណ្ឌទី១ និងទី៣ មាត្រា៧ នៃអនុក្រឹត្យលេខ ៣៧ អនក្របក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចក្នុងការរៀបចំនៅកន្លែងធ្វើការ ដើម្បីធានាថា កម្មករនិយោជិតអាចរក្សាគម្លាតសុវត្ថិភាពយ៉ាងតិចចំនួន ១,៥០ម៉ែត្រ ទាំងពេលចូលធ្វើការ និងពេលកំពុងធ្វើការ។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងអាគារនីមួយៗ គឺមានច្រកទ្វារចេញចូលច្រើនជាងមួយ ប៉ុន្តែជាការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកបើកច្រកទ្វារតែមួយប៉ុណ្ណោះ ដើម្បីឱ្យកម្មករនិយោជិតចេញ ចូលធ្វើការ គឺដើម្បីរក្សាសន្តិសុខ សុវត្ថិភាព និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទាំងមូល។ ម្យ៉ាងទៀត ដើម្បីបង្ការការឆ្លងជំងឺកូវីដ-១៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា និយោជកបានរៀបចំគម្លាតសុវត្ថិភាព ដោយមានការគូសគំនូសគម្លាតសុវត្ថិភាព និងមានរនាំងសម្រាប់កម្មករនិយោជិតនៅពេលចេញចូលអគារ ព្រមទាំងបានប្រកាសតាមរយៈឧបករណ៍បំពងសំឡេងអំពីការរក្សាគម្លាតសុវត្ថិភាព ដើម្បីបង្ការការប្រជ្រៀតគ្នា។ លើសពីនេះទៀត និយោជកក៏បានរៀបចំឡានរង់ចាំកម្មករនិយោជិតឡើងឡានអស់ ទើបនិយោជកអនុញ្ញាតឱ្យឡានចេញបាន ដើម្បីឆ្លើយតបនឹងការបារម្ភរបស់កម្មករនិយោជិត។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនមានមូលដ្ឋាន និងភស្តុតាងណាមួយជាក់លាក់ ដើម្បីបញ្ជាក់ថា ការអនុវត្តរបស់និយោជកក្នុងការបើកច្រកទ្វារតែមួយ គឺមិនត្រឹមត្រូវតាមមាត្រា ២ នៃច្បាប់ស្តីពីការងារ និងមាត្រា ៧ នៃអនុក្រឹត្យលេខ ៣៧ អនក្របក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ខាងលើនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចបើកច្រកទ្វារតាមអគារនីមួយៗ បន្ថែមចំនួន ១ទៀត នោះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកច្រកទ្វារតាមអគារនីមួយៗ បន្ថែមចំនួន ១ទៀត ដើម្បីឱ្យកម្មករនិយោជិតចេញចូលអគារ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីព ទៅតាមការស្នើសុំរបស់សមាជិកសហជីពកម្មករនិយោជិតចំនួន ២០០០រៀល ទៅឱ្យសហជីពកម្មករនិយោជិត ចាប់ពីខែកញ្ញា ឆ្នាំ២០២១**

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ចាប់តាំងពីខែឧសភា ឆ្នាំ២០២០ សហជីពកម្មករនិយោជិត បានដាក់បញ្ជីឈ្មោះកម្មករនិយោជិត និងលិខិតលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករចំនួន ១៥៧នាក់ ជូននិយោជក ដើម្បីកាត់ប្រាក់ភាគទានជូនសហជីពកម្មករនិយោជិត ប៉ុន្តែនិយោជកមិនព្រមកាត់ប្រាក់ភាគទានជូនសហជីពកម្មករនិយោជិតនោះទេ។ ដោយឡែក ភាគីនិយោជកបានអះអាងថា កន្លងមកនិយោជកមិនបានទទួលលិខិតលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករ តាមរយៈសហជីពកម្មករនិយោជិតនោះទេ ហើយប្រសិនបើនិយោជកបានទទួលលិខិតលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករត្រឹមត្រូវ និយោជក នឹងកាត់ប្រាក់ភាគទានជូន។

ករណីនេះ ប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើសហជីពកម្មករនិយោជិតបានបំពេញនីតិវិធី និងបែបបទនៃការស្នើសុំកាត់ប្រាក់ភាគទានសហជីពទៅនិយោជកត្រឹមត្រូវស្របតាមច្បាប់ដែរ ឬទេ?

THE ARBITRATION COUNCIL

មាត្រា ១២៩ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"អនុសញ្ញារួមដែលអនុញ្ញាតឱ្យដកហូតលើប្រាក់ឈ្នួលក្រៅពីករណីទាំងនេះ ត្រូវទុកជាមោឃៈដោយពេញច្បាប់។*

*ប៉ុន្តែ កម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិក។ ការអនុញ្ញាតនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអាចបដិសេធវិញបានគ្រប់ពេលវេលា"*។

កថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ ចែងថា ៖ *"និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលជាសមាជិកសហជីព ដើម្បីផ្ទេរទៅឱ្យសហជីពនោះជាស្វ័យប្រវត្តិក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត។ បែបបទអនុវត្តត្រូវកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ"*។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"កម្មករនិយោជិតអាចអនុញ្ញាតឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព។ ការអនុញ្ញាតនេះ ត្រូវធ្វើជាលាយលក្ខណ៍-អក្សរ នៅពេលដែលកម្មករនិយោជិតយល់ព្រមឱ្យនិយោជកកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក។ ចំពោះនីតិវិធី និងបែបបទនៃការកាត់ប្រាក់ភាគទាននេះ គឺត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ"*។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៣១/១៨-ខេន ស្តែត ស៊ូ ហេតុផលនៃចំណុចវិវាទទី៤, លេខ ០៣២/១៨-ខេន ស្តែត ស៊ូ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៦ និងលេខ ០៥៤/១៨-រូស៊ីង ហ្គាម៉ែន ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ប្រការ ១ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពី នីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ បានចែងថា ៖ *"សហជីពអាចស្នើសុំឱ្យនិយោជកកាត់ប្រាក់ភាគទានពីសមាជិករបស់ខ្លួនបាន លុះត្រាតែសហជីពនោះបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ស្តីពីសហជីព"*។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ហឺវ៉ាយហ្សិន អៅដរ (ខេមបូឌា) ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខចុះបញ្ជី ១០៤១៧០០២២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។ ហេតុនេះ សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ហឺវ៉ាយហ្សិន អៅដរ (ខេមបូឌា) មានសិទ្ធិស្នើសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលជាសមាជិកសហជីពសម្រាប់បង់ភាគទានសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ហឺវ៉ាយហ្សិន អៅដរ (ខេមបូឌា) បាន។

ទន្ទឹមនឹងនេះ កថាខណ្ឌទី២ ប្រការ ៤ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.ក.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ដដែលខាងលើ បានចែងថា ៖ *"សហជីពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់និយោជក ឱ្យបានយ៉ាងតិច ១០(ដប់)ថ្ងៃ មុនការចាប់ផ្តើមកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព អំពីចំនួនប្រាក់ភាគទានសហជីពដែលនឹងត្រូវកាត់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិករបស់ខ្លួន។ សហជីពត្រូវភ្ជាប់មកជាមួយនូវលិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព ដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមម្រាមដៃរបស់កម្មករនិយោជិតសាមី"*។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"សហជីពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់និយោជកឱ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលចាប់ផ្តើមកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសម្រាប់បង់ភាគទានសហជីព អំពីចំនួនប្រាក់ភាគទានដែលត្រូវកាត់ និងត្រូវមានភ្ជាប់មកជាមួយនូវ*

*លិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីពដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមម្រាមដៃរបស់កម្មករនិយោជិត "។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៣១/១៨-ខេន ស្ពត ស៊ូ ហេតុផលនៃចំណុចវិវាទទី៤, លេខ ០៣២/១៨-ខេន ស្ពត ស៊ូ ខូអិលធីឌី ហេតុផលនៃចំណុច វិវាទទី ៦ និងលេខ ០៥៤/១៨-រស៊ីង ហ្គាម៉ែន ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពកម្មករនិយោជិតបានដាក់លិខិតស្នើសុំកាត់ភាគទានសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ហឺរាយហ្សិន អៅជរ (ខេមបូឌា) ចុះថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០២០ ដោយមានភ្ជាប់ជាមួយនឹងបញ្ជីឈ្មោះកម្មករនិយោជិតដែលបានព្រមព្រៀងកាត់ភាគទាន ដោយមានចុះកាលបរិច្ឆេទ ឈ្មោះ និងស្នាមមេដៃរបស់កម្មករនិយោជិត ជូនភាគីនិយោជក។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតបានបំពេញនីតិវិធីនៃការជូនដំណឹងស្តីពីការស្នើសុំកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពទៅនិយោជកត្រឹមត្រូវស្របតាមប្រការ ៤ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.ក.ប.ក ខាងលើ។ លើសពីនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតក៏មានភ្ជាប់ជាមួយលិខិតស្តីពីការលាលែងពីសហជីពសិទ្ធិប្រយោជន៍កម្មករ និងការមិនអនុញ្ញាតឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីពសិទ្ធិប្រយោជន៍កម្មករចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ដាក់ទៅនិយោជកផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចកាត់ប្រាក់ភាគទានសហជីពស្របទៅតាមការស្នើសុំរបស់សមាជិកសហជីពកម្មករនិយោជិតចំនួន ២០០០រៀល ទៅឱ្យសហជីពកម្មករនិយោជិតសម្រាប់ខែកញ្ញា ឆ្នាំ២០២១ នៅពេលដែលភាគីកម្មករនិយោជិតបានបំពេញបែបបទ និងនីតិវិធីនៃការកាត់ប្រាក់ភាគទានសហជីពត្រឹមត្រូវស្របទៅតាមមាត្រា ២៦ នៃច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ និងប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីពទៅតាមការស្នើសុំរបស់សមាជិកសហជីពកម្មករនិយោជិតចំនួន ២០០០រៀល ទៅឱ្យសហជីពកម្មករនិយោជិត បន្ទាប់ពីកម្មករនិយោជិតបានបំពេញបែបបទ និងនីតិវិធីនៃការកាត់ប្រាក់ភាគទានសហជីព។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកច្រកទ្វារតាមអគារនីមួយៗ បន្ថែមចំនួន ១ទៀត ដើម្បីឱ្យកម្មករនិយោជិតចេញចូលអគារ។

**ចំណុចវិវាទទី ២ ៖**

- បង្គាប់ឱ្យនិយោជកកាត់ប្រាក់ភាគទានសហជីតាមការស្នើសុំរបស់សមាជិកសហជីពកម្មករនិយោជិតចំនួន ២០០០រៀល ទៅឱ្យសហជីពកម្មករនិយោជិត បន្ទាប់ពីកម្មករនិយោជិតបានបំពេញបែបបទ និងនីតិវិធីនៃការកាត់ប្រាក់ភាគទានសហជីព។

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **យូ សួនទី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ភុយ នាម**

ហត្ថលេខា ៖ ------------------------------